គំរោងអេកូសន
ECOSORN PROJECT

# ដំណាំសណ្តែកដី



គំរោងស្តារឡើងវិញលើវិស័យសេដ្ឋកិច្ច និង សង្គមកិច្ចនៅបណ្តាខេត្តនៃតំបន់ពាយ័ព្យ
Economic and Social Re-launch of Northwest Provinces (ECOSORN)
បានទទួលការណែនាំពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

Agricultural Development Denmark Asia

## ១.ការជ្រើសរើសពូជ

ដំណាំសណ្តែកដី តើកសិករសំគាល់លើលក្ខណៈពូជល្អដូចម្តេចដើម្បីដាំដុះឱ្យបានទិន្នផលខ្ពស់?

កត្តាពូជល្អកំណត់នូវទិន្នផលបានខ្ពស់ និងតំរូវការទីផ្សារមាន២ពូជ :

-ពូជស្រាល ១២០ថ្ងៃ

-ពូជធ្ងន់ ១៧០ថ្ងៃ

- ពូជធន់ជំងឺ និងសត្វល្អិត
- ពូជដែលផ្តល់ទិន្នផលខ្ពស់ និងតំរូវការទីផ្សារ
- ពូជមានអាយុកាលខ្លី
- ពូជដែលអាចរក្សាទុកបានទាំងសំបក
- ពូជដែលមានដំណុះចាប់ពី ៨៥ភាគរយឡើងទៅ ។

ពូជដំណាំសណ្តែកដីមាន៣ប្រភេទ ដែលប្រជាកសិករនៅប្រទេសកម្ពុជានិយមធ្វើការដាំដុះមាន:

- ពូជគ្រាប់ធំ
- ពូជសំបកឆ្នូត
- ពូជសំបករលីង ។

## ២.ការរៀបចំដី

- ដីល្បាយខ្សាច់ច្រោះទឹក pH ៦,៥-៧,៥
- ភ្ជួរដីហាលរយៈពេល៧-១៤ថ្ងៃមុនពេលដាំដុះ ឱ្យបាន១ ឬ ២ដងក្នុងជំរៅ១៥សម- ២០សម
- ភ្ជួរលើកទី២រួមទាំងការរាស់សំរេចឱ្យដីម៉ដ្ឋល្អ និងមានភាពរាបស្មើសំរាប់ធ្វើការដាំដុះ

## ៣.ការដាំ

វិធីសាស្ត្រដាំដុះដំណាំសណ្តែកដីមាន២យ៉ាងមាន:

-**ការដាំដោយលើករង** : ការដាំរបៀបនេះគេច្រើនអនុវត្តនៅក្នុងក្នុងរដូវវស្សា ដោយការលើករងក្រោយពីការរៀបចំដីដាំដុះ រួច (ក្នុងតំបន់វាលរាបមិនលិចទឹក) ។ តំរូវការគ្រាប់ពូជ: ចំនួន៨០គក្រក្នុង១ហិកតា ក្នុង១រណ្តៅដាក់ ១ - ២ គ្រាប់ ។

| ចន្លោះជួរ (ស.ម) | ចន្លោះគុម្ព(ស.ម) |
|---|---|
| ៥០ | ១៥-២០ |

-លើករងដាំចន្លោះគុម្ពពី ១,៥តឹក-២តឹក

-**ការដាំលាត** : គេអនុវត្តនៅរដូវប្រាំង និងរដូវវស្សាផងដែរ (តំបន់ខ្ពង់រាប, វាលរាប, ច្រាំងទន្លេ,...) ការដាំនៅ ដើមរដូវភ្លៀង និងចុងរដូវភ្លៀងត្រូវឧស្សាហ៍ត្រួតពិនិត្យ និង គ្រប់គ្រងសំណើមដីឱ្យបានល្អសំរាប់ការលូតលាស់ និងផ្កាផ្លែ បានពេញលេញ (៦០-៨០ភាគរយ) ។

## ៤.ការថែទាំ

### ការប្រើប្រាស់ជី

ការប្រើប្រាស់ជីតាមបច្ចេកទេស និងត្រឹមត្រូវតាមពេលវេលាដែលដំណាំត្រូវការ នាំមកនូវទិន្នផលខ្ពស់ និងរក្សាគុណភាពដីបានទៀតផង ។ ប្រភេទជីដែលអាចប្រើប្រាស់គឺជីគីមី និងជីធម្មជាតិ ។ ការប្រើប្រាស់ជីចែកចេញជាពីរដំណាក់កាលគឺដាក់ជីទ្រាប់បាតមុនពេលដាំ ដោយប្រើប្រាស់ជីលាមកសត្វ ១០-១៥តោន/ហិកតា និងជី១៥-១៥-១៥ពី១៥០គ.ក្រ២០០គក្រ/ហិកតា ដាក់ជីអាសូត ៥០% ហើយនៅសល់ ៥០%ទៀត ទុកដាក់ក្រោយដាំបាន ២៥ថ្ងៃ ។



**ការជំរះស្មៅ**

ការសំអាតស្មៅចង្រៃត្រូវអនុវត្តឱ្យបាន២ដងនិងទាន់ពេលវេលាធ្វើយ៉ាង ណាកុំឱ្យស្មៅដុះប្រជែងជាមួយដំណាំឱ្យសោះ ព្រោះការងារនេះបើយើងធ្វេសប្រហែស នឹងនាំឱ្យដំណាំបន្ថយការលូតលាស់ ហើយទិន្នផលក៏នឹងថយចុះទៅតាមនោះដែរ (មិនអាចកែបានឡើយ)

## ៥.សត្វល្អិត និងជំងឺ

**សត្វល្អិត** : ភាគច្រើនជួបសត្វស្រមោច ដង្កូវរមូរស្លឹក និងពពួកចៃ ។ល។ ពពួកស្រមោចច្រើនមាននៅពេលក្រោយ ដាំរួចហើយ ដង្កូវរមូរស្លឹក និងចៃមានកើតដំណាក់កាល លូតលាស់។

វិធានការការពារ និងកំចាត់ពួកវា គឺត្រូវសង្កេត តាមដានបរិស្ថានជុំវិញនៃការលូតលាស់របស់ដំណាំ មុនឈានដល់ការប្រើប្រាស់ថ្នាំពុលគីមីកសិកម្ម ។ កសិករចាំបាច់ណាស់ ត្រូវស្គាល់សត្វមានប្រយោជន៍ និងសត្វស៊ីដំណាំជាមូលដ្ឋានគ្រឹះនៃការដាំដុះដំណាំសណ្តែកដី ។

**ជំងឺលើដំណាំសណ្តែកដី** :ភាគច្រើនគេតែងតែជួបប្រទះជំងឺ

-ជម្ងឺផ្សិត Cercospora បង្កអោយមានស្នាមអុចមូលៗ លើស្លឹកធ្វើអោយទិន្នផលថយចុះ ២០% ការកំចាត់ប្រើថ្នាំ Minagro ២ ស្លាព្រាបាយលាយទឹក ១៨លីត្រ បាញ់រាល់៧ថ្ងៃម្តង។

-ជម្ងឺវីរុស Rosette ធ្វើអោយគ្រាប់មិនផ្តល់ផល (ប្រសិនកើតមាននៅមុនពេលចេញផ្កា) ការប្រើថ្នាំ Diazinon លាយកំរិត ២ ស្លាបព្រាបាយជាមួយទឹក ១៨លីត្របាញ់កំចាត់។

-ជម្ងឺអុចពណ៌ខ្មៅនៅលើស្លឹកនិងជំងឺបួសលឿងនិងជំងឺរលួយឫស ត្រូវប្រើ វិធានការពារ គឺកុំដាំដំណាំលើដី តែមួយ ច្រើនដង ឬប្រើពូជធន់ និងប្តូរមុខដំណាំផ្សេងទៀត ដែលខុសអំបូររបស់វាផងដែរឬដកយកទៅចោល ឬដុត ចោល ។

## ៦.ការប្រមូលផល

ប្រមូលផលដំណាំសណ្តែកដីក្នុងកំឡុងខែមីនាក្រោយពីការដុះចេញគិតទៅតាមពូជដែលបានធ្វើការដាំដុះ ។ ពេលប្រមូលផលនៅដំណាក់កាលដែលដំណាំសណ្តែកដីមានស្លឹកលឿងទុំ ច្រើន(៦០-៧០%) ។គេដកដើមសណ្តែកដី ដោយទាំងផ្លែពីក្នុងដីរួចគេធ្វើការហាលក្នុងរយៈពេល២-៣ថ្ងៃ រួចគេធ្វើការ ប្រលេះនិងបកយកគ្រាប់ជាបន្តបន្ទាប់ ។ប្រការដែលគួរ ជៀសវាងកុំទុកឱ្យស្ងួតដោយកំដៅខ្លាំងពេក ។ កុំដកដើមផ្លែស្រស់គរជាគំនរ ។ កុំហាលថ្ងៃយូរពេកក្រោយពេលដក ប្រមូលផល ។



**ឈ្មោះអ្នកទំនាក់ទំនង :**

**អាសយដ្ឋាន:** ភូមិកំពង់ស្វាយ ឃុំកំពុងស្វាយ ស្រុកសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

ទូរស័ព្ទលេខ: ០១៧ ៤៨៩ ១៥៨

**E-mail:** sovannaouk@yahoo.com